# គណបក្ស សិទ្ធិមនុស្ស

# HUMAN RIGHTS PARTY

បំរើ ការពារ កសាង

លេខ.០០៣៧/១០..គ.ស.ម

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០

## សេចក្តីបំភ្លឺ

**គណបក្សសិទ្ធិមនុស្ស** មានសេចក្តីសោកស្តាយយ៉ាងខ្លាំងចំពោះមតិមួយចំនួនដែលធ្វើជាពុំយល់អ្វីសោះពីបំណងរបស់គណបក្សសិទ្ធិមនុស្ស ដែលបានស្នើសុំ ពន្យារពេលចំនួន២សប្តាហ៍ សម្រាប់ពិចារណាលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ។ អ្នកសារព័ត៌មាន អ្នកនយោបាយខ្លះបែរជានិយាយដោយពុំមានវិចារណញ្ញាណថា យើងពុំមានបំណងចង់ឲ្យច្បាប់ប្រឆាំងអំពើពុករលួយនោះចេញរួចទៅវិញ ។ ការនិយាយដោយបំណងនៃអ្នកទាំងនោះ គឺគាត់ពុំយល់ពាក្យ ពន្យារពេល២សប្តាហ៍ នេះឬអ្វី ? គណបក្សសិទ្ធិមនុស្សមានបំណងយ៉ាងខ្លាំងក្លា ដើម្បីឲ្យមានច្បាប់ប្រឆាំងអំពើពុករលួយដើម្បីអាចទាញជនពុករលួយយកទៅធ្វើទោសតាមទំហំនៃការបំផ្លាញជាតិរបស់ពួកនោះ ហើយឲ្យពួកនោះសងមកវិញនូវអ្វីៗដែលគេបានប្លន់ពីពលរដ្ឋខ្មែរ និងប្រទេសខ្មែរ ។ ប៉ុន្តែយើងស្នើពន្យារពេលនេះ ព្រោះយើងយល់ថា ច្បាប់នេះព្រាងអស់រយៈពេល១៦ឆ្នាំ ហើយស្រាប់តែយកមកឲ្យអ្នកតំណាងរាស្ត្រពិនិត្យ សិក្សាតែរយៈពេលមិនដល់មួយសប្តាហ៍ផង (គិតទាំងថ្ងៃសៅរ៍ អាទិត្យ និងទិវានារីអន្តរជាតិ) ឃើញថាវាមានភាពតក់ក្រហលណាស់ ហើយវានឹងមិនបំរើឲ្យប្រយោជន៍ប្រជាពលរដ្ឋទូទៅឡើយ ។ ទន្ទឹមនេះពុំមានតែគណបក្សសិទ្ធិមនុស្សទេ ដែលយល់ថាត្រូវពន្យាពេលនោះ សូម្បីតែអង្គការក្រៅរដ្ឋាភិបាលមួយចំនួនធំក៏យល់ដូចយើងដែរ ។

ហេតុនេះ សូមអ្នកនយោបាយ និងសារព័ត៌មានមួយចំនួនយល់ឲ្យបានច្បាស់ និងកុំឆ្លៀតយកការសុំពន្យារពេល២សប្តាហ៍ ទៅបកស្រាយដើម្បីលាក់ល្បិចកលទុច្ចរិតរបស់ខ្លួននោះ ។

សូមឲ្យអ្នកនយោបាយ និងសារព័ត៌មានប្រកាន់យកផលប្រយោជន៍ជាតិ និងប្រជារាស្ត្រជាធំ កុំបំភ័ន្តបំភ្លៃ កុហក បោកប្រាស់ប្រជារាស្ត្រយើង ។/

HUMAN RIGHTS PARTY

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*

*ទូរស័ព្ទលេខ ៖ 011 777 750*

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com| Website: www.hrpcambodia.info